សួស្តីមិត្តភក្តិទាំងអស់គ្នា ជួបជាមួយខ្ញុំម្តងទៀតហើយក្នុងការនិយាយអំពីរដូវភ្លៀង នៅជនបទម្តង។ នៅជនបទបានន័យថានៅស្រុកស្រែ។ បាទ ដូច្នេះកុំឲ្យខាតពេលយូរខ្ញុំសូមបកស្រាយ និងរៀបរាប់ដូចតទៅ។ នៅជនបទ ពេលដែលមានភ្លៀងម្តងៗ គឺអ្នកស្រែតែងតែសប្បាយចិត្តទៅនឹងទឹកភ្លៀង។ បាទ ព្រោះតែទឹកភ្លៀងនេះ គឺធ្វើឲ្យផលដំណាំរបស់គាត់ ដូចជាការដាំស្រូវ ដូចជាការដាំដំឡូង ដូចជាការដាំល្ង ដូចជាការដាំផលដំណាំផ្សេងៗហ្នឹង គឺវាលូតលាស់ គឺវាអំណោយផលបានយ៉ាងល្អ។ បាទ ហើយពេលដែលភ្លៀងម្តងៗ គឺថាអ្នកស្រុកអ្នកស្រែគឺតែងតែ ទទួលយកទឹកភ្លៀងនោះទុកប្រើប្រាស់។ បាទ ដូចជាពេលភ្លៀងមក គឺគេមានទទឹកសម្រាប់ទ្រ[...] ទនោះ គឺគេដាក់ទពីលើដំបូលផ្ទះ រហូតមកដល់ក្រោម បាទ គឺពេលដែលទឹកភ្លៀងវាហូរមក វាហូរចូលទៅក្នុងពាង។ បាទ ដូច្នេះគេអាចទុកទឹកនោះប្រើប្រាស់ បាទ ប្រើប្រាស់ដូចជាការដាំស្ល ដូចជាការដាំទឹកញ៉ាំ និយាយរួមគឺការប្រើប្រាស់ផ្សេងៗតាមតម្រូវការរបស់គេ។ ហើយអ្នកខ្លះទៀតនោះ ក៏យកទឹកភ្លៀងនោះយកទៅត្រងទុក បាទ ទុករយៈពេល ១០ ថ្ងៃ ឬមួយក៏ ៥ ថ្ងៃ អញ្ចឹងទៅ[?]ពួកគេយកមកបរិភោគ យកមកផឹក[...]។ បាទ ហើយភ្លៀង បាទ ពេលដែលភ្លៀងមក គឺស្រូវ អីហ្នឹងគឺវាបានផលល្អ ពីព្រោះអីពេលដែលភ្លៀងមក ពេលដែលមុនដំបូង ពេលដែលភ្លៀងមក គឺគេភ្ជួររាស់ដី បាទ ភ្ជួររាស់ដី ពេលដែលភ្លៀងមកមួយសាទៀត គឺគេចាប់ផ្តើម បាទ បាចស្រូវ បាចអីអញ្ចឹងទៅ ដើម្បីឲ្យវាហ្នឹងមានសំណាបក្នុងការដក។ ពេលដែលសំណាបហ្នឹងល្អហើយ គឺគេបានយកវាហ្នឹងដក[...] ដើម្បីដាំវាពូនក្លាយជាស្រូវ។ បាទ ហើយបើសិនជាវាល្អ ឬមួយក៏មិនល្អ គឺអាស្រ័យទៅលើទឹកភ្លៀងដែរ។ បាទ ដូចជា ឧទាហរណ៍ ដូចជាឆ្នាំនេះផ្ទាល់ គឺទឹកភ្លៀងនៅកម្ពុជា មិនសូវជាមានទេ [...] ខ្ញុំគិតថានៅឆ្នាំនេះ នៅប្រទេសកម្ពុជា នឹងខ្វះខាតស្បៀង បានន័យថានឹងខ្វះខាតអាហារ និងខ្វះខាតបាយញ៉ាំ ហើយអង្ករគឺត្រូវតែឡើងថ្លៃ ព្រោះថាឆ្នាំនេះ គឺមិនសូវមានទឹកភ្លៀង ហើយប្រជាពលរដ្ឋ គាត់ក៏បានដឹងអំពីបញ្ហានេះ ហើយគាត់អ្នកខ្លះហ្នឹង គឺមិនបានធ្វើស្រែទេឆ្នាំនេះ រីឯអ្នកខ្លះទៀតហ្នឹងក៏បានធ្វើស្រែ ប៉ុន្តែធ្វើស្រែដោយដីទទេ គឺគ្មានទឹកទាល់តែសោះ។ បាទ ដូច្នេះរឿងនេះ គឺជារឿងមួយមិនមែនធម្មតាទេ គឺជារឿងកង្វល់របស់ប្រជាជនកម្ពុជាទូទាំងប្រទេសតែម្តង។ បាទ ហើយមួយទៀតពេលដែលភ្លៀងអញ្ចឹងនៅស្រុកស្រែគឺ វាមិនសូវជាមានថ្នល់ជាតិទេ មានថ្នល់ចាក់កៅស៊ូអីអញ្ចឹងទេ វាមានតែផ្លូវលំ ផ្លូវក្រួសក្រហមអីអញ្ចឹង ផ្លូវភក់ អីអញ្ចឹង[...] បាទ ហើយពេលដែលយើងធ្វើដំណើរ [...] ភក់ហ្នឹងវាខ្ទាត មកប្រឡាក់អាវរបស់យើង ឬមួយក៏ពេលដែលភក់នោះ អញ្ចឹងទៅ ធ្វើឲ្យយើងរអិលដួល។ បាទ ហើយខ្លះណាទៀតនោះ ដីនៅកន្លែងហ្នឹងបើសិនជាមានទឹកហូរខ្លាំង វាធ្វើឲ្យដីកន្លែងហ្នឹងបាក់អីអញ្ចឹងទៅ ឬមួយក៏នៅលើស្ពានអីអញ្ចឹងទៅ ធ្វើឲ្យដីនោះបាក់ ហើយទឹកហូរលឿន ទឹកហូរក្ដួចអីអញ្ចឹង ប្រជាជនមានលក្ខណៈភ័យ ដូច្នេះពួកគេក៏កាត់បន្ថយពេលដែលភ្លៀង ពួកគេមិនសូវចេញដើរទេ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បាទ ប៉ុន្តែមានប្រជាជនមួយចំនួនពេលដែលភ្លៀងមក ពួកគេបែរជាកាន់ចប កាន់ធុង បាទ ដើរទៅរក ដើរទៅរកអី ដូចជាខ្យង ដូចជាក្តាម អីអញ្ចឹងនៅតាមវាលស្រែ បាទ នោះគឺជាគ្រោះថ្នាក់ម្យ៉ាងដែរ ព្រោះថានៅតាមវាលស្រែ វាមានចរន្តស្រូបជាច្រើន ដូចជាចរន្តខ្សែ អ៊ីនធើណេត ខ្សែកាបទូរទស្សន៍អីអញ្ចឹង វាមានចរន្តច្រើន ដូច្នេះវាធ្វើឲ្យមានរន្ទះបាញ់ ឬមួយក៏អីអញ្ចឹងទៅ វាអាចនឹងឆក់យើង។ បាទ ហើយរន្ទះបាញ់ នឹងបាញ់យើងមួយរំពេចហ្នឹងតែម្តង។ ដូច្នេះ ការបាត់បង់ជីវិតហ្នឹង នឹងមានលក្ខណៈលឿនមែនទែន។ បាទ ដូច្នេះយើង គប្បីយើងពេលដែលភ្លៀង យើងគួរតែនៅផ្ទះ បាទ គប្បីយើងមិនគួរចេញដើរទៅវាលស្រែ ឬមួយក៏ចេញដើរទៅរកខ្យង ឬមួយក៏រកក្តាមអីទេ បាទ ព្រោះថាវាធ្វើឲ្យយើងមានគ្រោះថ្នាក់។ បាទ ហើយអ្នកខ្លះទៀត ពេលដែលទឹកភ្លៀងមក គឺគេបានយកអាគុយរបស់គេ បានយកអាគុយរបស់គេហ្នឹង យកទៅត្រងទឹកភ្លៀង ឬមួយក៏យកអាគុយរបស់គេហ្នឹង ទៅលាងទឹកភ្លៀង ឬមួយក៏បើកគម្របទឹកអាស៊ីតហ្នឹង ចាក់ទឹកភ្លៀងចូល ព្រោះថានៅក្នុងទឹកភ្លៀងហ្នឹងវាមានជាតិអាស៊ីតដែរ បាទ ដូច្នេះគេធ្វើឲ្យអាគុយហ្នឹងកាន់ភ្លើងអីអញ្ចឹងទៅ។ បាទ អាគុយហ្នឹងគឺ ជាវត្ថុម្យ៉ាងសម្រាប់ចាប់ឲ្យមានភ្លើងដូចអគ្គិសនីអញ្ចឹង ប៉ុន្តែវាមានរូបរាង ៤ ជ្រុង បាទ វាមានរូបរាង ៤ ជ្រុង បាទ ហើយវាមានប្រដាប់សម្រាប់?]ចាប់ពីរ គឺ ចាប់មួយបូក គឺចាប់មួយដក។ បាទ ចាប់បូកនោះ គឺពណ៌ក្រហម រីឯចាប់ដកនោះ គឺពណ៌ខ្មៅអីអញ្ចឹងទៅ។ បាទ ដូច្នេះគឺខ្ញុំរៀបរាប់បានតែត្រឹមហ្នឹងទេ។ ដូច្នេះខ្ញុំសូមបញ្ចប់នូវការរៀបរាប់ នូវរដូវទឹកភ្លៀងនៅក្នុងជនបទតែត្រឹមនេះសិន។ បាទ សូមអរគុណ សូមជម្រាបលា។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.